# ឧបទេសសំរាប់និយោជិត ត្រឡប់ទៅធ្វើការវិញ

ពិធីការត្រឹមត្រូវ ដើម្បីត្រឡប់ទៅធ្វើការវិញ គួរតែបានប្រព្រឹត្តតាម បន្ទាប់ពីការបង្ខាំងខ្លួន ឬការនៅដាច់ឡែក របស់និយោជិត ដើម្បីបន្ថយហានិភ័យ នៃការរាលដាលជំងឺ COVID-19 នៅក្នុងការដ្ឋាន។

## តើនិយោជិត គួរតែបង្ខាំងខ្លួន នៅពេលណា?

បើសិនគេបានធ្វើដំណើរ ទៅក្រៅរដ្ឋម៉ាស្សាជូសេត្ត ក្នុងពេល 10 ថ្ងៃកន្លងមក ឬបានរងអានុភាពពីអ្នកណាម្នាក់ ដែលវិជ្ជមាន COVID-19 សូម្បីតែបើគេមិនបង្ហាញរោគសញ្ញា និងមិនបានធ្វើតេស្ត ដោយវិជ្ជមានរោគក៏ដោយ។

## តើនិយោជិត គួរតែនៅដាច់ឡែក នៅពេលណា?

បើសិនគេបានធ្វើតេស្ត ដោយវិជ្ជមាន COVID-19 ឬមានរោគសញ្ញាអ្វីមួយនៃ COVID-19 (សូម្បីតែធុនស្រាល)។

## តើគេអាចត្រឡប់ទៅធ្វើការវិញ នៅពេលណា?

និយោជិតទាំងអស់ ដែលឋិតក្នុងការនៅដាច់ឡែក ឬបង្ខាំងខ្លួន មិនគួរត្រឡប់ទៅធ្វើការវិញឡើយ លុះត្រាតែគេស្របតាម លក្ខណៈខាងក្រោម៖

### បើសិននិយោជិត បានឋិតក្នុងការបង្ខាំងខ្លួន

**ដោយព្រោះបានដឹងការរងអានុភាព**

- បន្ទាប់ពីការបង្ខាំងខ្លួន សំរាប់ពេលដែលបានតម្រូវ*
- ***សំរាប់អ្នកធ្វើការថែទាំសុខភាព អ្នកតបឆ្លើយដំបូង និងអ្នកធ្វើការហេដ្ឋារចនាសម្ព័ន្ធសំខាន់៖***
    - អ្នកធ្វើការវិស័យខ្លះ អាចនឹងបន្តទៅធ្វើការ អំឡុងពេលបង្ខាំងខ្លួន ដើម្បីរក្សាមុខងារសំខាន់ **ដរាបតែបើសិនគេនៅតែឥតមានរោគសញ្ញាជាដដែល។**
    - អ្នកធ្វើការ ត្រូវតែយ៉ាងហោចពាក់របាំងមុខ និងឧបករណ៍ការពារខ្លួនសមរម្យ ជាបន្ថែមនៅកន្លែងធ្វើការ និងត្រួតមើលរោគសញ្ញា ដោយខ្លួនឯង

**ដោយព្រោះធ្វើដំណើរ ទៅក្រៅរដ្ឋម៉ាស្សាជូសេត្ត**

- បង្ខាំងខ្លួនចំនួន 10 ថ្ងៃ* **ឬ** មានលទ្ធផលអវិជ្ជមាន COVID-19

### បើសិននិយោជិត បានឋិតក្នុងការនៅដាច់ឡែក

**រោគសញ្ញាធុនស្រាល – មធ្យម**

- យ៉ាងហោច 24 ម៉ោង ដោយគ្មានគ្រុន (ដោយគ្មានប្រើថ្នាំបន្ថយគ្រុន); និង
- យ៉ាងហោច 10 ថ្ងៃ ចាប់តាំងពីរោគសញ្ញាបានចាប់ផ្តើម; និង
- ការធូរស្បើយនូវរោគសញ្ញា

**រោគសញ្ញាធ្ងន់ធ្ងរ (បានតម្រូវការដេកពេទ្យ)**

- និយោជិត គួរតែប្រឹក្សាជាមួយអ្នកជំនាញខាងជំងឺឆ្លង
- នៅដាច់ឡែក ដល់ទៅ 20 ថ្ងៃ

**ឥតមានរោគសញ្ញា**

- យ៉ាងហោច 10 ថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទ នៃការធ្វើតេស្តវិជ្ជមានរោគ COVID-19 ដំបូង; និង
- មិនបានកើតមានរោគសញ្ញា ជាបន្តបន្ទាប់មកទៀត

**និយោជិត មិនគួរតម្រូវនូវលទ្ធផលធ្វើតេស្ត COVID-19 ឬលិខិតពីអ្នកថែទាំសុខភាព សំរាប់និយោជិតដែលឈឺថ្កាត់ ដើម្បីបញ្ជាក់ជំងឺរបស់គេ សំរាប់សិទ្ធិទទួលការឈប់ឈឺ ឬត្រឡប់មកធ្វើការវិញឡើយ។**

** សំរាប់សេចក្តីពិស្តារពេញលេញ ស្តីពីពេលវេលាបង្ខាំងខ្លួន យោងតាមការធ្វើតេស្ត ឬការកើតមានរោគសញ្ញា ទស្សនា mass.gov/QuarantineTime*

សំរាប់ព័ត៌មានថែមទៀត ស្តីពីការបង្ខាំងខ្លួន និងការនៅដាច់ឡែក ទស្សនា **mass.gov/isol8**